CITY OF LONG BEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ២៨ ខែមេសាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចស្វែងរកយោបល់ពីសហគមន៍តាមរយៈ ReopenLB ការស្ទង់មតិតាមអ៊ិនធឺរណែត

ទីក្រុងឡុងប៊ិចរដ្ឋកាលីហ្វ័រញ៉ា — ថ្ងៃនេះទីក្រុងឡុងប៊ិចបានបើកការស្ទង់មតិតាមអ៊ិនធឺរណែតមួយឈ្មោះ ReopenLB ដើម្បីស្វែងរកយោបល់រួមពីប្រជាពលរដ្ឋ អ្នកធ្វើការ និងម្ចាស់អាជីវកម្មអំពីវិធីបើកសេដ្ឋកិច្ចក្នុងតំបន់ឡើងវិញដោយសុវត្ថិភាពនៅពេលបទបញ្ជារបស់លោកអភិបាលរដ្ឋ Newsom បង្ហាញថាការធ្វើដូច្នេះនឹងមានសុវត្ថិភាព។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "ការស្ទង់មតិសម្រាប់ការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់យើងផ្តល់ឱ្យអ្នកស្រុកនិងអ្នកជំនួញក្នុងតំបន់នូវឱកាសដើម្បីផ្តល់យោបល់ចំពោះវិធីបើកសេដ្ឋកិច្ចឡុងប៊ិចឡើងវិញតាមវិធីដែលមានសុវត្ថិភាពបំផុត។ យើងគិតថាគំនិតល្អបំផុតនិងគំនិតច្នៃប្រឌិតថ្មីបំផុតនឹងកើតចេញពីម្ចាស់អាជីវកម្មខ្នាតតូចដែលស្គាល់មុខជំនួញនិងអតិថិជនរបស់ពួកគេ។"

សំណួរស្ទង់មតិនឹងសួរអ្នកឆ្លើយថាតើពួកគេមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការត្រឡប់ទៅធ្វើការឬបើកអាជីវកម្មរបស់ពួកគេឡើងវិញឬទេនិងអំពីអ្វីដែលពួកគេចាត់ទុកថាជាសកម្មភាពដែលមានហានិភ័យទាប។ លទ្ធផលនឹងត្រូវប្រមូលនិងចែករំលែកជាមួយក្រុមប្រឹក្សាក្រុង។ រាល់ការសំរេចចិត្តទាក់ទងនឹងការបើកទីតាំងឡើងវិញគឺត្រូវអនុលោមតាមបទបញ្ជា "ស្នាក់នៅផ្ទះ" របស់លោកអភិបាលរដ្ឋ

Newsom និងបទបញ្ជារបស់មន្ត្រីសុខាភិបាលនៃទីក្រុងឡុងប៊ិចប៉ុន្តែការផ្តល់យោបល់ពីសហគមន៍នឹងត្រូវបានចាត់ទុកជាផ្នែកមួយនៃយុទ្ធសាស្ត្រសម្រាប់ការបើកអាជីវកម្មដែលមានហានិភ័យទាបនិងសកម្មភាពកម្សាន្ត។ ព័ត៌មានទំនាក់ទំនងរបស់អ្នកចូលរួមស្ទង់មតិអាចត្រូវបានប្រើសម្រាប់សំណួរតាមដានពីបុគ្គលិកក្រុងប្រសិនបើចាំបាច់ប៉ុន្តែនឹងមិនត្រូវបានចែកចាយជាសាធារណៈទេ។

ប្រជាពលរដ្ឋអាចចាប់ផ្តើមផ្តល់យោបល់ភ្លាមៗដោយចូលទៅកាន់គេហទំព័រ www.longbeach.gov/ReopenLB។ បណ្តាញភ្ជាប់សម្រាប់ការស្ទង់មតិនេះក៏នឹងត្រូវចែកចាយតាមរយៈបណ្តាញជាច្រើនរួមមាន អ៊ីម៉ែល ប្រព័ន្ធផ្សព្វផ្សាយសង្គម និងអង្គការសហគមន៍ផ្សេងៗ។ ចម្លើយស្ទង់មតិនឹងត្រូវបានប្រមូលរហូតដល់ម៉ោង ៥ ល្ងាចនៅថ្ងៃច័ន្ទទី ៤ ខែឧសភា។

ReopenLB គឺជាកិច្ចខិតខំប្រឹងប្រែងមួយក្នុងចំណោមការខិតខំជាច្រើនរបស់ទីក្រុងដើម្បីចូលរួមជាមួយសហគមន៍និងទូទាត់ផលប៉ះពាល់សេដ្ឋកិច្ចនៃជំងឺកូវីដ-១៩។ សកម្មភាពផ្សេងទៀតរួមមានការបង្កើតមូលនិធិសង្គ្រោះគ្រោះមហន្តរាយឡុងប៊ិចដែលជាកញ្ចប់ជំនួយសេដ្ឋកិច្ចដ៏ទូលំទូលាយមួយដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាក្រុងកាលពីថ្ងៃទី ១៤ ខែមេសា ការចាប់ផ្តើមនៃកម្មវិធី Work Long Beach នៅ Pacific Gateway និងការបង្កើតក្រុមប្រឹក្សាស្តារសេដ្ឋកិច្ច។ ទីក្រុងឡុងប៊ិចក៏បានបង្កើតបណ្តាញទូរស័ព្ទបន្ទាន់សម្រាប់ម្ចាស់អាជីវកម្មនិងនិយោជិកនៅលេខ 562.570.4BIZ (4249) ដែលមានបុគ្គលិកចាំលើកចាប់ពីម៉ោង ៨ ព្រឹកដល់ ៥ ល្ងាចពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

###